# ស្ត្រីវិស័យសំណង់ក្នុងប្រទេសកម្ពុជា

## ការងាររបស់ពួកគេ - ចំណេះដឹងរបស់ពួកគេ - សុវត្ថិភាពរបស់ពួកគេ

ច្រើនជាង៣០%នៃកម្មករសំណង់ក្នុងប្រទេសកម្ពុជាគឺជាស្ត្រី។ការសិក្សារបស់អង្គការឃែរបានបញ្ជាក់ថាកម្មការិនីទាំងនោះមានចំណេះដឹងតិចតួចថាច្បាប់ប្រទេសកម្ពុជាក៏គ្របដណ្តប់លើពួកគេដែរ។ ការសន្មត់អំពីជំនាញ និងសមត្ថភាពរបស់ស្ត្រីបានធ្វើឱ្យស្ត្រី និងបុរសត្រូវបានគេចាត់ទុកក្នុងសភាពមួយខុសប្លែកគ្នា ស្ត្រីជានិច្ចកាលត្រូវបានផ្តល់ឱ្យនូវតួនាទីតូចតាច ទទួលបានប្រាក់កម្រៃទាប និងមិនសូវទទួលបានការផ្តល់តម្លៃ ឬមិនត្រូវបានគេទទួលស្គាល់ ។ អង្គការឃែរកំពុងធ្វើការក្នុងភាពជាដៃគូជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការក្នុងស្រុក ដើម្បីលើកកម្ពស់ការយល់ដឹងរបស់កម្មការិនី និងដោះស្រាយនូវការសន្មត់នានាអំពីសមត្ថភាពរបស់ស្ត្រី ធ្វើដូចនេះកម្មការិនីសំណង់នៅកម្ពុជា អាចទទួលបានកន្លែងធ្វើការមានសុវត្ថិភាព និងបង្កើននូវឱកាសការងារផងដែរ ។

### ពួកគេជានរណា

**តាមការសិក្សាបានបង្ហាញថាភាគច្រើននៃស្ត្រីកម្មករសំណង់គឺរៀបការរួច (៧២%) លើសពីអាយុ ៣០ឆ្នាំ (៧៨%) មានការសិក្សាកម្រិតបឋមតិចតួច ឬគ្មាន (៧៧%)។**

- ស្ត្រីទាំងអស់បំលាស់ទីពីខេត្តផ្សេងៗគ្នា ដើម្បីធ្វើការសំណង់។ ភាគច្រើនព្រោះតែពួកគេក្រីក្រ ឬពុំមានការងារផ្សេងទៀត ដែលនៅជិតៗផ្ទះរបស់ពួកគេ។
- ច្រើនជាង ២៥% ធ្វើការតាមរដូវកាល និងច្រើនជាស្ត្រី (៧៨%) បានកំពុងធ្វើការក្នុងវិស័យសំណង់ដែលតិចជាង៣ឆ្នាំ ហើយ ៤២% បម្រើការងារតិចជាង១ឆ្នាំ។
- ស្ត្រីជាច្រើនមកធ្វើការតាមស្វាមី ឬសាច់ញាតិរបស់ពួកគេក្នុងសំណង់។
- តែ ២០% នៃស្ត្រីធ្វើការក្នុងសំណង់ជាសមាជិកសហជីព។

### ការងាររបស់ពួកគេ

**មានការបែងចែកការងារសំណង់ច្បាស់តាមរយៈយេនឌ័ររបស់បុរសនិងស្ត្រីនៅប្រទេសកម្ពុជា**

- បុរសធ្វើការងារធ្ងន់ជាង ការងារគ្រោះថ្នាក់ជាង និងការងារមានជំនាញ ខណៈពេលដែលស្ត្រីធ្វើការងារមិនចំណាយកម្លាំងកាយច្រើន ការងារលម្អិតដែលទាមទារភាពអត់ធ្មត់ គេចាត់ទុកថាសមចំពោះស្ត្រី មិនមែនបុរស ។
- លើសពី១ភាគ៣នៃស្ត្រីធ្វើ "ការងារលម្អិត" ដូចជាចងដែក បៀករ៉ង ឬការងារស្រីៗដូចជាសម្អាតកន្លែង ។
- ភាគច្រើន (៧៣%) នៃស្ត្រីធ្វើការងារពីរបីក្នុងពេលតែមួយដូចជា យោង រៀប និងកាន់សម្ភារៈសំណង់ ឧ. ឥដ្ឋ ខ្សាច់ និងស៊ីម៉ង់ ទៅឱ្យកម្មករបុរស គឺដូចជាការងារជំនួយការ ។
- ច្រើនជាង ៥០% នៃស្ត្រីនិយាយថាពួកគេមិនដែលបានបណ្តុះបណ្តាល ឬមិនដែលបានទទួលឱកាសបណ្តុះបណ្តាល និងឡើងឋានៈដូចបុរសនោះទេ ។

### ប្រាក់ឈ្នួលរបស់ពួកគេ

**ស្ត្រី៩នាក់ក្នុងចំណោម១០នាក់បានរាយការណ៍ថា ពួកគេទទួលបានកម្រៃតិចជាងបុរសពី១ដុល្លា ដល់៣ដុល្លា ក្នុងតួនាទីការងារដូចគ្នា។**

- ស្ត្រី៣នាក់ក្នុងចំណោម៤នាក់បានកម្រៃពីចន្លោះ ៣.៧៥ដុល្លា និង៥ដុល្លាក្នុង១ថ្ងៃ។ ខណៈពេលតែ១០% រកកម្រៃបាន ៦.២៥ដុល្លា ស្រដៀងទៅនឹងកម្មករបុរសដែលទទួលបានកម្រៃទាប ។
- ប្រធានគ្រប់គ្រង និងប្រធានផ្នែកក្រុមហ៊ុនជាច្រើន ចូលចិត្តរើសកម្មករបុរស ព្រោះពួកគេអាច "ធ្វើការសំណង់បានច្រើនប្រភេទខុសគ្នា" ហើយជាទូទៅគេយល់ថាមានជំនាញច្រើនជាងស្ត្រី ។
- អត្រាប្រាក់កម្រៃស្ត្រីទាបជាង តាមការពន្យល់របស់ស្ត្រីកម្មករដែលកំពុងធ្វើការក្នុងសំណង់ "ការងារប្រើកម្លាំងតិចៗ(ស្រាលៗ) ដូច្នេះសរុបមកការងារ "តិច" ចំពោះការងារទូទៅ ។
- ត្រឹមតែ ២៨% នៃស្ត្រីនិយាយថា ពួកគេរកកម្រៃបានគ្រប់គ្រាន់សម្រាប់ការចំណាយប្រចាំថ្ងៃ និង១ភាគ៣ នៃស្ត្រីទាំងអស់ពុំមានលុយសន្សំទេ

### ចំណេះដឹងរបស់ពួកគេ

**ស្ត្រីធ្វើការក្នុងសំណង់មានចំណេះដឹងតិចតួចអំពីសិទ្ធិរបស់ពួកគេស្របតាមច្បាប់ស្តីពីការងារ**

- ការសិក្សាបានបង្ហាញថាប្រហែលជាពាក់កណ្តាលនៃស្ត្រី មិនដឹងថាលក្ខខណ្ឌការងាររបស់ពួកគេស្ថិតក្រោមច្បាប់ស្តីពីការងារ ឬយ៉ាងណា និងមាន១៨% ជឿថាមិនបានគ្របដណ្តប់នោះទេ ។
- ៩២% មិនបានទទួលព័ត៌មានលាយលក្ខអក្សរចំពោះលក្ខខណ្ឌការងារតាំងពីថ្ងៃចាប់ផ្តើមការងារ និងច្រើនជាងពាក់កណ្តាល (៥៤%) មិនបានទទួលព័ត៌មានផ្ទាល់មាត់អំពីលក្ខខណ្ឌការងាររបស់គេទេ
- ៨៥% ធ្វើការ៨ម៉ោងឬតិចជាងនេះ ៧៦% ទទួលបានការឈប់សម្រាក១ថ្ងៃក្នុង១សប្តាហ៍ និងពួកគេទាំងអស់បើកប្រាក់កម្រៃប្រចាំសប្តាហ៍ ឬ២សប្តាហ៍ម្តង ជាទូទៅវាអនុលោមទៅតាមច្បាប់ការងារ
- ស្ទើរតែគ្មានស្ត្រីណាម្នាក់ដែលធ្វើការក្នុងសំណង់យល់អំពីទស្សនៈ ថ្ងៃឈប់សម្រាកបុណ្យ សម្រាកប្រចាំឆ្នាំ ឈប់លំហែមាតុភាព និងឈប់ដោយជម្ងឺ ដែលមានប្រាក់ឈ្នួលនោះទេ ។

## សុវត្ថិភាពការងាររបស់ពួកគេ

### មានរឿងជាច្រើនដែលគួរតែចាប់ផ្តើមធ្វើ ដើម្បីធានាថាមានសុវត្ថិភាពនៅក្នុងការដ្ឋាន ជាពិសេសចំពោះស្ត្រី

- ពាក់កណ្តាលនៃស្ត្រីពុំបានទទួលឧបករណ៍សុវត្ថិភាព ឬសំលៀកបំពាក់សុវត្ថិភាពពីក្រុមហ៊ុនរបស់ពួកគេទេ ហើយប្រសិនបើមាន ១ភាគ៣ នោះត្រូវបង់លុយសម្រាប់ឧបករណ៍នោះតាមប្រាក់ឈ្នួលរបស់ពួកគេផ្ទាល់
- ៩២% នៃស្ត្រីមិនបានទទួលវគ្គអប់រំអំពីសុវត្ថិភាពដែរ ឬបើមានក៏មានវគ្គអប់រំតែរយៈពេលយ៉ាងតិចជាង១ម៉ោងប៉ុណ្ណោះ
- តាមការសិក្សា ១ភាគ៣ នៃស្ត្រីនិយាយថា កូនក្មេងត្រូវបានអនុញ្ញាតិឲ្យចូលក្នុងការដ្ឋាន
- ៣២% ជាស្ត្រីប្រាប់ថាបានឃើញការបៀតបៀនផ្លូវភេទចំពោះស្ត្រីកម្មករផ្សេងទៀត ជាមួយគ្នានេះស្ត្រីនៅលីវហាក់បីដូចជាមានបទពិសោធន៍ទ្វេដងចំពោះការបៀតបៀនផ្លូវភេទជាងស្ត្រីរៀបការរួច

## លក្ខខណ្ឌនៃការរស់នៅរបស់ពួកគេ

### ៤០% នៃស្ត្រីកម្មករមិនមានអារម្មណ៍ថាលក្ខខណ្ឌនៃការរស់នៅរបស់ពួកគេមានសុវត្ថិភាព និងអំពើហឹង្សាក្នុងគ្រួសារគឺជារឿងសាមញ្ញ

- ជាក់ស្តែងស្ត្រីទាំងអស់ធ្វើការក្នុងសំណង់ រស់នៅផ្ទះបណ្តោះអាសន្នដែលផ្តល់ដោយក្រុមហ៊ុន ឬរស់នៅក្បែរការដ្ឋាន ជាមួយនឹងកម្មករផ្សេងទៀតច្រើនជាង១០០០នាក់
- ៣៦% នៃស្ត្រីមានបទពិសោធន៍ពីអំពើហិង្សាផ្លូវចិត្ត ហិង្សាផ្លូវកាយ ឬហិង្សាផ្លូវភេទពីស្វាមីរបស់គេ ឬដៃគូស្និទ្ធស្នាលរបស់ពួកគេ ក្នុងរយៈពេល១២ខែចុងក្រោយនេះ
- ៧៤% នៃស្ត្រីទទួលស្គាល់ថាបុរសមានហេតុផលក្នុងការវាយដំប្រពន្ធរបស់ពួកគេយ៉ាងហោចណាស់ហេតុផលមួយ ហើយក៏មានស្ត្រីម្នាក់ក្នុងចំណោម៤នាក់បដិសេធរាល់ទម្រង់នៃអំពើហិង្សាក្នុងគ្រួសារ
- ១នាក់ ក្នុងចំណោម ៥នាក់ បានរាយការណ៍ថា លក្ខខណ្ឌនៃការរស់នៅរបស់ពួកគេពុំមានសុវត្ថិភាព ពីព្រោះអ្នកជិតខាងរបស់ពួកគេប្រើហិង្សាក្នុងគ្រួសារ និងមានបុរសប្រើប្រាស់គ្រឿងស្រវឹង
- ថ្វីបើមានការផ្តល់នូវបង្គន់ និងបន្ទប់ទឹកពីសំណាក់ក្រុមហ៊ុន ប៉ុន្តែពុំមានអនាម័យ និងពេលខ្លះមិនគ្រប់គ្រាន់

## ការធ្វើការសម្រេចចិត្តរបស់ពួកគេ

### ការងារអាចជាប្រភពនៃភាពអង់អាចរបស់ស្ត្រី និងគ្រប់គ្រងលើការសម្រេចចិត្ត និងបញ្ហាហរិញ្ញវត្ថុ គឺមានទ្រង់ទ្រាយសំខាន់ទាក់ទងនឹងសមភាពយេនឌ័រ

- ស្ត្រី៧នាក់ក្នុង១០នាក់ បានចូលរួមសម្រេចចិត្តលើការចំណាយលុយដែលពួកគេរកបាន ខណៈពេលដែល ៧% មិនបាននិយាយ
- ភាគច្រើននៃស្ត្រីដែលបានចូលរួមសម្រេចចិត្តលើការទិញសម្ភារៈសំខាន់ៗក្នុងផ្ទះ (៨៨%) និងការថែទាំសុខភាព(៨៦%)។

ការងាររបស់អង្គការឃែរគឺកំពុងជួយស្ត្រី និងនិយោជកនានាឱ្យយល់ដឹងអំពីរបៀបបង្កើនចំនួនកម្មការិនីដែលមានជំនាញដែលស្ត្រីគួរចេះ ដើម្បីផ្តល់ឱ្យឧស្សាហកម្មសំណង់។

- អ្នកដឹកនាំមិត្តអប់រំមិត្តចំនួន៤០នាក់កំពុងពង្រឹងការយល់ដឹងរបស់ស្ត្រីទៅលើផ្នែកសំខាន់ៗដូចជាការគ្រប់គ្រងថវិការបស់ពួកគេ សុខភាព សុវត្ថិភាព និងអនាម័យ ការកាត់បន្ថយជម្លោះនៅផ្ទះ និងការអភិវឌ្ឍន៍ខ្លួននៅកន្លែងធ្វើការ។
- អង្គការដៃគូនានារបស់អង្គការឃែរកំពុងធ្វើការគាំទ្រស្ត្រី ដើម្បីធានាថា ពួកគេមានសុវត្ថិភាព និងទទួលបានភាពសមរម្យនៅកន្លែងធ្វើការ ។
- ម្ចាស់ក្រុមហ៊ុនសំណង់ អ្នកគ្រប់គ្រង និងមេការ កំពុងធ្វើការជាមួយអង្គការឃែរដើម្បីស្វែងយល់នូវអ្វីដែលពួកគេអាចធ្វើបានដើម្បីការពារស្ត្រីនៅកន្លែងធ្វើការ និងលើកទឹកចិត្តឱ្យមានការចូលរួមពីស្ត្រី ដូច្នេះពួកគេអាចរក្សាកម្មករកម្មការិនីជំនាញបានទាំងអស់។

care®

សហភាពអឺរ៉ុប

WITH FUNDING FROM
AUSTRIAN DEVELOPMENT COOPERATION

ព័ត៌មានទាំងអស់នេះដកស្រង់ពីការស្រាវជ្រាវដែលបានធ្វើឡើងដោយលោកស្រីខារ៉ូស្ទ្រីកឃ្លើរ និងលោកពូសុវណ្ណសម្រាប់គម្រោងសិទ្ធិការងារកម្មការិនីសំណង់របស់អង្គការឃែរដែលបានមូលនិធិសហភាពអឺរ៉ុប និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេសអូទ្រីស។គម្រោង៣ឆ្នាំនេះមានគោលបំណងដើម្បីពង្រឹងសម្ថតភាពដល់កម្មការិនីសំណង់ សង្គមស៊ីវិល និងរដ្ឋាភិបាលស្តីពីសិទ្ធិការងារ និងបង្កើនសំឡេងនិង ឥទ្ធិពលនៃការធ្វើការរបស់ស្ត្រីក្នុងសំណង់។
ការសិក្សាស្រាវជ្រាវនេះធ្វើឡើងពីខែឧសភា ដល់ខែមិថុនា ឆ្នាំ២០១៦ ដោយប្រើប្រាស់វិធីសាស្ត្របែបបរិមាណ និងគុណភាព។

ការផ្សាយចេញជាសាធារណៈគឺជាការទទួលខុសត្រូវរបស់អង្គការឃែរកម្ពុជាតែមួយគត់ ហើយព័ត៌មានទាំងនេះមិនមានការឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ប្រទេសអូទ្រីសទេ។